# សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណាខ្ញុំបាទ **ព្រុំ សុខា** និងប្អូនស្រី **ព្រុំ ឆោមសាយឿន** រួមជាមួយប្អូនៗ និងកូនចៅទាំងអស់ ព្រមទាំងក្រុមញាតិគ្រួសារ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅប្រគេនព្រះថេរានុថេរៈ និងជូនចំពោះសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនពុទ្ធបរិស័ទ និងញាតិមិត្តជិតឆ្ងាយដែលបានចូលរួមរំលែកមរណទុក្ខនិងចូលរួមពិធីបុណ្យសព **ឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត ចាន់ ស៊ីវ៉ាន់ថា អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល** ដែលបានទទួលមរណភាពកាលពីថ្ងៃសៅរ៍ ៨រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ០០:៣០នាទី ក្នុងជន្មាយុ ៦៧ឆ្នាំ ដោយរោគាពាធ។

ការចូលរួមប្រកបដោយកាយវិការសន្តោសប្រណី និងពោរពេញទៅដោយសទ្ធាជ្រះថ្លាស្មោះស្ម័គ្រនៅក្នុងពិធីបុណ្យទក្ខិណានុប្បទានទាំងនៅគេហដ្ឋាន ក៏ដូចជាពិធីដង្ហែទៅធ្វើឈាបនកិច្ចនៅវត្តជ្រោយអំពិល ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលបានញ៉ាំងឱ្យពិធីបុណ្យសពរបស់ប្អូនជាទីស្រលាញ់របស់ខ្ញុំបាទ សពស្វាមីជាទីស្រលាញ់របស់នាងខ្ញុំ បានប្រព្រឹត្តទៅតាមទំនៀមទំលាប់ប្រពៃណីព្រះពុទ្ធសាសនាយ៉ាងមហោឡារិកអធិកអធមជាទីបំផុត គឺជាកាយវិការប្រកបដោយសមានចិត្តស្រលាញ់រាប់អានដ៏ជ្រាលជ្រៅរបស់ព្រះថេរានុថេរៈ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី បងប្អូនពុទ្ធបរិស័ទ និងញាតិមិត្តជិតឆ្ងាយ ចំពោះខ្ញុំព្រះករុណាខ្ញុំបាទ នាងខ្ញុំ និងក្រុមញាតិគ្រួសារ។

ខ្ញុំព្រះករុណាខ្ញុំបាទ នាងខ្ញុំ និងក្រុមញាតិគ្រួសារ សូមបួងសួងគុណព្រះរតនត្រៃ និងវត្ថុស័ក្តសិទ្ធិក្នុងលោកជួយបីបាច់ថែរក្សាព្រះថេរានុថេរៈ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី បងប្អូនពុទ្ធបរិស័ទនិងញាតិមិត្តជិតឆ្ងាយទាំងអស់ សូមប្រកបដោយសេចក្តីសុខសេចក្តីចំរើនគ្រប់ប្រការ និងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។